ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

១៣៤៣
០៣-០៥-១៧
០៤:០០

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣១១
ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦
សំណុំរឿងជំនុំជម្រះលេខ ១៦៧
ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧
សាលក្រមលេខៈ ០៣ "ឆ.២"
ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

# នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាអសាធារណៈនៅសាលាដំបូងខេត្តសៀមរាប។
កាលបរិច្ឆេទបើកសវនាការ ៖ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៧ ។
កាលបរិច្ឆេទប្រកាសសាលក្រមជាអសារណៈ ៖ នៅថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០១៧។

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈ ចៅក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈ ចៅក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ឋានៈព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៣១១ អ.ក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ៖

១. ឈ្មោ [redacted] គីមឡុង ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរស៊ីស្ស កើតនៅភូមិទក្សិណខាងត្បូង ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាបកាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៧ មានទីលំនៅភូមិទក្សិណខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។ ក្នុងឃុំ

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៨៨/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

២. ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៨ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិទក្សិណខាងត្បូង សង្កាត់ គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី០២ មុខរបរគ្មាន ទីលំនៅសព្វថ្ងៃនៅភូមិទក្សិណខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុន គ្មាន។ (ក្នុងឃុំ)



Scanned by CamScanner

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៨៩/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

៣. ឈ្មោះ [redacted] ជំនោរ ភេទប្រុស អាយុ២១ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី០៨ មុខរបរគ្មាន ទីលំនៅសព្វថ្ងៃ នៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៩០/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

៤. ឈ្មោះ [redacted] ឌីណា ភេទស្រី អាយុ១៦ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជ្រៃ ឃុំខ្ចាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី០៧ ទីលំនៅសព្វថ្ងៃនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៩១/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

ត្រូវជាប់ចោទពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥. ឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ ជាជនត្រូវចោទ មុខរបរ កម្មករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិទក្សិណត្បូង ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ ទី០៦ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (គេចខ្លួន)

៦. ឈ្មោះ [redacted] វ៉ាន់និត ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ ជាជនត្រូវចោទ មុខរបរ គ្មាន កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិខ្មៀន ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅ បច្ចុប្បន្ននៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៧ ឪពុកឈ្មោះ [redacted] (រ)ម្ដាយ ឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ត្រូវជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

- លោក [redacted] តឹមហួរ មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] តឹមឡុង និង [redacted] ឌីណា ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ០៩/២០១៧ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។



Scanned by CamScanner

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៣៨ ពស.ព្រស/២០១៧ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង១៧និង២០នាទី ស្ថិតនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្លាំងសមត្ថកិច្ចបានចុះល្បាតលើដងផ្លូវ បានប្រទះឃើញឈ្មោះ [redacted] ជំនោរ និងឈ្មោះ [redacted] ឌីណា ហៅ ម៉ី ហើយសមត្ថកិច្ចបានធ្វើការសួរចម្លើយ ពួកគេបានសារភាពថា ពួកគេពិតជាបានធ្វើសកម្មភាពប្រើប្រាស់ថ្នាំញៀន ប្រភេទម៉ាទឹកកកពិតប្រាកដមែន ដែលថ្នាំញៀននេះពួកគេបានចូល លុយគ្នាទិញពីឈ្មោះ [redacted] មួត , ឈ្មោះ [redacted] ហ៊ីម និងមនុស្សប្រុសមិនស្គាល់ឈ្មោះប្រើប្រាស់លេខទូរស័ព្ទ ០៦៩៧៩៥៩៧២ និងលេខ ០៩៨ ៩៦៤ ៨៩៨ ។ ក្រោយពីធ្វើការសួរចម្លើយហើយ សមត្ថកិច្ចបានបន្តធ្វើ ការឃាត់ខ្លួនឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] គីមឡុង ហើយពួកគេទាំងពីរនាក់បានឆ្លើយសារភាពថា ពួកគេ ពិតជាធ្លាប់ប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក ពិតប្រាកដមែន ដោយថ្នាំញៀននោះពួកគេបានចូលលុយគ្នា ទិញពីឈ្មោះ [redacted] ហ៊ីម ។

## នាពេលសវនាការ

១.ជនជាប់ចោទឈ្មោះ [redacted] គីមឡុង បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួន កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ពេលខ្លួនកំពុងជិះម៉ូតូដើរលេង ដោយសារប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ទិញពីឈ្មោះ [redacted] ហ៊ីម តម្លៃ ១០០០០រៀល ទៅ ២០០០០រៀល បានបួនលើក យកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] រដ្ឋា ទើបប្រើប្រាស់ ០៤ដង មកពីដើរតាមគេ។ ខ្លួនអត់ដែលចាត់ចែងឲ្យគេប្រើប្រាស់គ្រឿងញៀនទេ ថ្នាំញៀន ឈ្មោះ [redacted] រដ្ឋា ជាអ្នកទិញ ពេលសមត្ថកិច្ចឃាត់ខ្លួនអត់បានដកហូតអ្វីទេ ខ្លួនទទួលយកបទប្រើប្រាស់គ្រឿងញៀន។ ខ្លួនទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] រដ្ឋា ចូលលុយគ្នាទិញម្នាក់ ១០០០០រៀល ពីឈ្មោះ [redacted] ហ៊ីម ស្គាល់លេខទូរស័ព្ទតាមគេ។ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ជំនោរ និងឈ្មោះ [redacted] ឌីណា ទេ។ បន្ទាប់ពីទិញថ្នាំញៀនរួច យកមកប្រើប្រាស់ជាមួយគ្នា។

២.ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានឆ្លើយថា៖ ខ្លួន និងឈ្មោះ គីមឡុង ទៅទិញថ្នាំញៀនជាមួយគ្នា ចូលលុយគ្នាទិញ នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ចំពោះឧបករណ៍ប្រើប្រាស់ជួយគ្នាធ្វើ។ ពេលសមត្ថកិច្ចចាប់ខ្លួន អត់បានប្រើប្រាស់គ្រឿងញៀនទេ ខ្លួនប្រើប្រាស់គ្រឿងញៀនបាន ០៤ដង ជាមួយឈ្មោះ គីមឡុង ខ្លួននិងឈ្មោះ គីមឡុង ទៅទិញថ្នាំញៀនជាមួយគ្នា ០៤ដង អត់ដែលទៅម្នាក់ឯងទេ លុយចូលគ្នា ពេលខ្លះលុយរបស់ឈ្មោះ ឡុង អ្នកលក់នៅភូមិជាមួយគ្នា អត់គេទាក់ទងទិញទេ ដើរទៅទិញ ចេះប្រើប្រាស់តាមគេ ខ្លួនជាអ្នកនាំឈ្មោះ គីមឡុង ប្រើប្រាស់។ ថ្នាំញៀននេះ ខ្លួនទិញពីឈ្មោះ ហ៊ីម អត់បានទិញពីអ្នកផ្សេងទេ អត់ដែលស្គាល់ឈ្មោះ [redacted] វ៉ាន់និត ទេ។

៣.ជនជាប់ចោទឈ្មោះ [redacted] ជំនោរ បានឆ្លើយថា៖ ថ្នាំញៀនដែលប្រើប្រាស់ទិញពីមនុស្សមិន



Scanned by CamScanner

ស្គាល់ តាមឈ្មោះ ហ៊ីម ឲ្យលេខ លើលុយតាមវីង ខ្លួនអ្នកទាក់ទងទិញផ្ទាល់ តម្លៃ ១០ម៉ឺនរៀល លុយរបស់ឈ្មោះ ធូរ ទៅទិញគ្នា ០៣នាក់។ ខ្លួនអត់ដឹងថាជាប់ប៉ុន្មានរឿងទេ ជាប់បានមួយខែ គេហៅមកសួរទៀត ពេលឃាត់ខ្លួនអត់បានដកហូតអ្វីទេ។ ខ្លួនធ្លាប់ទិញពីឈ្មោះ [redacted] មូត ម្តង ។

៤. ជនជាប់ចោទឈ្មោះ [redacted] ឌីណា បានឆ្លើយថា៖ ខ្លួនបានទិញថ្នាំញៀនពីមនុស្សមិនស្គាល់ គេតាមទូរស័ព្ទ បានលេខពីឈ្មោះ ហ៊ីម តម្លៃ ១០ម៉ឺនរៀល ជក់ជាមួយឈ្មោះ [redacted] ជំនោរ និងឈ្មោះ ធូរ លុយជារបស់ឈ្មោះ ធូរ ឲ្យទិញយកមកប្រើប្រាស់ ចេះប្រើប្រាស់គ្រឿងញៀនកាលពីខែតុលា ឆ្នាំ២០១៦ ចេះប្រើប្រាស់ដោយសារធ្វើការងារយប់ងងុយដេក។ ខ្លួនអត់ដែលស្គាល់អ្នកលក់ទេ ស្គាល់តាមឈ្មោះ ហ៊ីម ត្រូវជាមិត្តរបស់ឈ្មោះ ជំនោរ ខ្លួនក៏ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ហ៊ីម ផងដែរ។ ខ្លួនអត់ដែលស្គាល់ឈ្មោះ [redacted] វ៉ាននិត ទេ។ ចំពោះឧបករណ៍ប្រើប្រាស់ គឺឈ្មោះ ជំនោរ និងឈ្មោះ ហ៊ីម អ្នកធ្វើ។

៥. ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់និត្ត បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួននៅមុំខាងក្រោយខេរ៉េកក៉ក។ កន្លងមក ខ្លួនអត់ដែលលក់គ្រឿងញៀនទេ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន។ ខ្លួនមានបងប្អូន ០៧នាក់ អត់ស្គាល់ទេ អត់ប្រើប្រាស់ទូរស័ព្ទទេ ប្រើប្រាស់មួយខ្សែ អត់ចាំលេខ បងប្អូនជាប់ពន្ធនាគារជាមួយ ០៣នាក់ ។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយនាពេលសវនាការ ពិនិត្យអង្គហេតុ និងតាមការពិនិត្យភស្តុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទបានសារភាពថាពិតជាបានប្រព្រឹត្តអំពើ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមែន ដែលថ្នាំញៀនប្រើប្រាស់ទិញពីឈ្មោះ ហ៊ីម ចំណែកឈ្មោះ [redacted] វ៉ាននិត បានឆ្លើយលាក់បាំងការពិត ពុំអាចឲ្យតុលាការជឿជាក់បាន ដូច្នេះ តំណាងអយ្យការនៅរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ព្រមទាំងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ហ៊ីម ។
- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] គីមឡុង និង [redacted] ឌីណា ធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនជាអនីតិជន ហើយនាពេលសវនាការក៏បានឆ្លើយសារភាពការពិត ទទួលស្គាល់កំហុស ដូចនេះ សុំឲ្យតុលាការជួយបន្ធូលបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] គីមឡុង ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] ជំនោរ ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] ឌីណា ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយ



Scanned by CamScanner

បន្ធូរបន្ថយទោសផង។

- ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់និត ធ្វើសំណូមពរជាសម្ដីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
  - ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ។
  - ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។
  - ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ។
  - ក្រោយបានស្ដាប់សំណូមពរជាសម្ដីចុងក្រោយបង្អស់របស់ជនជាប់ចោទ។
  - ក្រោយពីបានពិនិត្យកស្ដុតាងជាឯកសារ និងកំណត់ហេតុផ្សេងៗ។
  - ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងខេត្តសៀមរាប**

**យល់ឃើញថា**

១.កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ថិតនៅចំណុចភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ជនជាប់ចោទឈ្មោះ [redacted] ជំនោរ ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] ឌីណា ភេទស្រី អាយុ ១៦ឆ្នាំ ,ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] គឹមឡុង ភេទប្រុស អាយុ ១៨ឆ្នាំ បានធ្វើសកម្មភាពចូលលុយគ្នា និងបានទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] វ៉ាន់និត ភេទប្រុស អាយុ ២៦ឆ្នាំ ដើម្បីយកមកប្រើប្រាស់ជាមួយគ្នា និងបានសហការគ្នារៀបចំឧបករណ៍សម្រាប់ប្រើប្រាស់។

២.ជនជាប់ចោទឈ្មោះ [redacted] គឹមឡុង បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួន កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ពេលខ្លួនកំពុងជិះម៉ូតូដើរលេង ដោយសារប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ទិញពីឈ្មោះ [redacted] ហ៊ីម តម្លៃ ១០០០០រៀល ទៅ ២០០០០រៀល បានបួនលើក យកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] រដ្ឋា ទើបប្រើប្រាស់ ០៤ដង មកពីដើរតាមគេ។ ខ្លួនអត់ដែលចាត់ចែងឲ្យគេប្រើប្រាស់គ្រឿងញៀនទេ ថ្នាំញៀន ឈ្មោះ [redacted] រដ្ឋា ជាអ្នកទិញ ពេលសមត្ថកិច្ចឃាត់ខ្លួនអត់បានដកហូតអ្វីទេ ខ្លួនទទួលយកបទប្រើប្រាស់គ្រឿងញៀន។ ខ្លួនទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] រដ្ឋា ចូលលុយគ្នាទិញម្នាក់ ១០០០០រៀល ពីឈ្មោះ [redacted] ហ៊ីម ស្គាល់លេខទូរស័ព្ទតាមគេ។ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ជំនោរ និងឈ្មោះ [redacted] ឌណា ទេ។ បន្ទាប់ពីទិញថ្នាំញៀនរួច យកមកប្រើប្រាស់ជាមួយគ្នា។

៣.ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានឆ្លើយថា ខ្លួន និងឈ្មោះ គឹមឡុង ទៅទិញថ្នាំញៀនជាមួយគ្នា ចូលលុយគ្នាទិញ នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ចំពោះឧបករណ៍ប្រើប្រាស់ជួយគ្នាធ្វើ។ ពេលសមត្ថកិច្ចចាប់ខ្លួន អត់បានប្រើប្រាស់គ្រឿងញៀនទេ ខ្លួនប្រើប្រាស់គ្រឿងញៀនបាន ០៤ដង ជាមួយឈ្មោះ គឹមឡុង ខ្លួននិងឈ្មោះ គឹមឡុង ទៅទិញថ្នាំញៀនជាមួយគ្នា ០៤ដង អត់ដែលទៅម្នាក់ឯងទេ លុយចូលគ្នា ពេលខ្លះលុយរបស់



Scanned by CamScanner

ឈ្មោះ ឡុង អ្នកលក់នៅភូមិជាមួយគ្នា អត់តេទាក់ទងទិញទេ ដើរទៅទិញ ចេះប្រើប្រាស់តាមគេ ខ្លួនជាអ្នកនាំឈ្មោះ តឹមឡុង ប្រើប្រាស់។ ថ្នាំញៀននេះ ខ្លួនទិញពីឈ្មោះ ហ៊ីម អត់បានទិញពីអ្នកផ្សេងទេ អត់ដែលស្គាល់ឈ្មោះ[redacted] វ៉ាន់និត ទេ។

៤. ជនជាប់ចោទឈ្មោះ[redacted]ជំនោរ បានឆ្លើយថា ថ្នាំញៀនដែលប្រើប្រាស់ទិញពីមនុស្សមិនស្គាល់ តាមឈ្មោះ ហ៊ីម ឲ្យលេខ វេលុយតាមវីង ខ្លួនអ្នកទាក់ទងទិញផ្ទាល់ តម្លៃ ១០ម៉ឺនរៀល លុយរបស់ឈ្មោះ ធូរ ទៅទិញគ្នា ០៣នាក់។ ខ្លួនអត់ដឹងថាជាប់ប៉ុន្មានរឿងទេ ជាប់បានមួយខែគេហៅមកសួរទៀត ពេលឃាត់ខ្លួនអត់បានដកហូតអ្វីទេ។ ខ្លួនធ្លាប់ទិញពីឈ្មោះ[redacted]មួក ម្តង។

៥. ជនជាប់ចោទឈ្មោះ[redacted] ឌីណា បានឆ្លើយថា ខ្លួនបានទិញថ្នាំញៀនពីមនុស្សមិនស្គាល់ គេតាមទូរស័ព្ទ បានលេខពីឈ្មោះ ហ៊ីម តម្លៃ ១០ម៉ឺនរៀល ដក់ជាមួយឈ្មោះ[redacted] ជំនោរ និងឈ្មោះ ធូរ លុយជារបស់ឈ្មោះ ធូរ ឲ្យទិញយកមកប្រើប្រាស់ ចេះប្រើប្រាស់គ្រឿងញៀនកាលពីខែតុលា ឆ្នាំ២០១៦ ចេះប្រើប្រាស់ដោយសារធ្វើការងារយប់ងងុយដេក។ ខ្លួនអត់ដែលស្គាល់អ្នកលក់ទេ ស្គាល់តាមឈ្មោះ ហ៊ីម ត្រូវជាមិត្តរបស់ឈ្មោះ ជំនោរ ខ្លួនក៏ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ហ៊ីម ផងដែរ។ ខ្លួនអត់ដែលស្គាល់ឈ្មោះ[redacted] វ៉ាននិត ទេ។ ចំពោះឧបករណ៍ប្រើប្រាស់ គឺឈ្មោះ ជំនោរ និងឈ្មោះ ហ៊ីម អ្នកធ្វើ។

៦. ជនជាប់ចោទឈ្មោះ[redacted] វ៉ាននិត បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួននៅម្តុំខារ៉ាអូខេរ៉ោកវ៉ាក។ កន្លងមក ខ្លួនអត់ដែលលក់គ្រឿងញៀនទេ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន។ ខ្លួនមានបងប្អូន ០៧នាក់ អត់ស្គាល់ទេ អត់ប្រើប្រាស់ទូរស័ព្ទទេ ប្រើប្រាស់មួយខ្សែ អត់ចាំលេខ បងប្អូនជាប់ពន្ធនាគារជាមួយ ០៣នាក់ ។

៧. ផ្អែកតាមចម្លើយរបស់ឈ្មោះ[redacted] តឹមឡុង និងឈ្មោះ[redacted]រដ្ឋា នាពេលសវនាការឃើញថា នៅថ្ងៃកើតហេតុ ពួកខ្លួនបានទៅទិញថ្នាំញៀនទាំងអស់គ្នាពីឈ្មោះ[redacted] ហ៊ីម ដោយបានចូលលុយគ្នាទិញម្នាក់ ១០០០០រៀល ចំនួន ០១កញ្ចប់តូច បន្ទាប់មក ក៏បាននាំគ្នារៀបចំឧបករណ៍ប្រើប្រាស់នៅផ្ទះរបស់ឈ្មោះ ហ៊ីម តែម្តង។ ចម្លើយនេះ គឺប្រហាក់ប្រហែលគ្នាទៅនឹងចម្លើយផ្សេងទៀត ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលអាចឲ្យតុលាការជឿជាក់បាន។

៨. ផ្អែកតាមចម្លើយរបស់ឈ្មោះ[redacted] ជំនោរ និងឈ្មោះ[redacted] ឌីណា នាពេលសវនាការឃើញថា នៅថ្ងៃកើតហេតុ គឺពួកខ្លួនបានទៅទិញថ្នាំញៀនពីជនមិនស្គាល់ឈ្មោះ ដែលស្គាល់តាមរយៈឈ្មោះ[redacted] ហ៊ីម ហើយលុយដែលទិញថ្នាំញៀនជារបស់ឈ្មោះ ធូរ បន្ទាប់ពីទិញថ្នាំញៀនបានហើយ ក៏នាំគ្នារៀបចំឧបករណ៍ប្រើប្រាស់ទាំងអស់គ្នាតែម្តង។ ចម្លើយនេះ គឺប្រហាក់ប្រហែលគ្នាទៅនឹងចម្លើយផ្សេងទៀត ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលអាចឲ្យតុលាការជឿជាក់បាន។

៩. ផ្អែកតាមចម្លើយជនជាប់ចោទឈ្មោះ[redacted] តឹមឡុង ,ឈ្មោះ[redacted] រដ្ឋា ,ឈ្មោះ[redacted]ជំនោរ និង



Scanned by CamScanner

ឈ្មោះ [redacted] ឌីណា បានបញ្ជាក់ថា ថ្នាំញៀនដែលបានទិញយកមកប្រើប្រាស់នោះ គឺបានទិញពីឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ ៣០ឆ្នាំ ។ ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានរត់គេចខ្លួន និងមានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៣៦៦/១៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

១០. តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វ៉ាន់និត នាពេលសវនាការឃើញថា ជនជាប់ចោទពុំបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនទេ គឺបានបដិសេធនូវការចោទប្រកាន់របស់តុលាការ ដែលជាចម្លើយលាក់បាំងនូវការពិតនូវអំពើដែលខ្លួនបានប្រព្រឹត្ត ដែលពុំអាចឲ្យតុលាការជឿជាក់បានទេ ព្រោះផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] ជំនោរ បានបញ្ជាក់ថា ធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ [redacted] មូត បានម្តង។ តាមរបាយការណ៍របស់សមត្ថកិច្ច បានផ្តល់សាវតាជាតិរបស់ជនជាប់ចោទថា ឈ្មោះ [redacted] វ៉ាន់និត ហៅក្រៅ មូត ភេទប្រុស កើតឆ្នាំ១៩៩០ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិខ្វៀន ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ឯម "រ" ម្តាយឈ្មោះ [redacted] នួម "រ" នៅលីវ។ បើពិនិត្យផ្ទៀតផ្ទាត់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជំនោរ និងភស្តុតាងឃើញថា ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់និត ភេទប្រុស អាយុ ២៦ឆ្នាំ ដែលបានបង្ហាញខ្លួននាពេលសវនាការ គឺពិតជាជនជាប់ចោទដែលបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។ ជនជាប់ចោទរូបនេះ បានរត់គេចខ្លួន និងមានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៣៦៥/១៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ ប៉ុន្តែជននេះត្រូវបានឃុំខ្លួននៅក្នុងសំណុំរឿងផ្សេង និងត្រូវបានបង្គាប់ឲ្យពន្ធនាគារយកមកធ្វើការពិភាក្សាដេញដោលនាពេលសវនាការជាសាធារណៈ។ តុលាការនឹងបង្គាប់ឲ្យបញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនពាបអំណាចសាលក្រមនេះ។

១១. ជនជាប់ចោទឈ្មោះ [redacted] ជំនោរ ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ១៨ឆ្នាំ ,ឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] វ៉ាន់និត ភេទប្រុស អាយុ ២៦ឆ្នាំ គឺជានីតិជន ដែលមានស្មារតី ដឹងខុសត្រូវគ្រប់គ្រាន់ដូច្នេះ រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់។

១២. ជនជាប់ចោទឈ្មោះ [redacted] ឌីណា ភេទស្រី អាយុ ១៦ឆ្នាំ និងឈ្មោះ [redacted] គឹមឡុង ភេទប្រុស អាយុ ១៨ឆ្នាំ ជាអនីតិជន ប៉ុន្តែតាមកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ឃើញថា ជនជាប់ចោទមានស្មារតីយល់ដឹងខុសត្រូវ នូវអំពើដែលខ្លួនបានប្រព្រឹត្ត ដូច្នេះ រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់។

១៣. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គមជាតិ ព្រមទាំងបំពានលើច្បាប់ជាធរមានរបស់រដ្ឋ ។

១៤. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំរក្សាបទចោទប្រកាន់ និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ព្រមទាំងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]



Scanned by CamScanner

ហុម ដើម្បីយកមកអនុវត្តទោស ។ តុលាការយល់ឃើញថា ការប្តឹងចោទប្រកាន់របស់តំណាងអយ្យការ គឺមានទំនាក់ទំនងអង្គហេតុ និងអង្គច្បាប់ ដើម្បីគាំទ្រដល់ការចោទប្រកាន់លើជនជាប់ចោទ។ តុលាការពិចារណា។

១៥.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] គឹមឡុង និងឈ្មោះ [redacted] ឌីណា បានធ្វើសេចក្តីសន្និដ្ឋានការពារស្នើសុំតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនជាអនីតិជន។តុលាការនឹងពិចារណាលើការបន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំងពីរនាក់ តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៦.មានភស្តុតាងបញ្ជាក់ពីពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ជំនោរ ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] ឌីណា ភេទស្រី អាយុ ១៦ឆ្នាំ ,ឈ្មោះ [redacted] វដ្ដា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] គឹមឡុង ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្នៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៧.មានភស្តុតាងបញ្ជាក់ពីពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] វ៉ាន់និត ភេទប្រុស អាយុ ២៦ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្នៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៨.វត្ថុចាប់យក ស្រោមសំបុត្រពណ៌ខ្ចីមខ្មៅ បិទជិតមានស្នាមមេដៃជនត្រូវចោទឈ្មោះ ឆុន វដ្ដា ចំនួន ០១ (ឧបករណ៍ប្រើប្រាស់គ្រឿងញៀន) ដូចក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ ៤៤២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ តុលាការនឹងសម្រេចរឹបអូស តាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>ហេតុដូច្នេះ ទនិច្ឆ័យសេចក្ត</u>

១. ផ្តន្ទាទោសជនជាប់ចោទះ

**ក**.ឈ្មោះ [redacted] គឹមឡុង ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន <u>០១(មួយ)ឆ្នាំ</u> ។

**ខ**.ឈ្មោះ [redacted] ឌីណា ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន <u>០១(មួយ)ឆ្នាំ</u> ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្នៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យ



Scanned by CamScanner

គ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

គ.ឈ្មោះ [redacted] វង្ហា ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន 0២(ពីរ)ឆ្នាំ អនុវត្តទោស ០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ទោសនៅសល់ត្រូវព្យួរធម្មតា ។

ឃ.ឈ្មោះ [redacted] ជំនោរ ភេទប្រុស អាយុ២១ឆ្នាំ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន 0២(ពីរ)ឆ្នាំ អនុវត្តទោស ០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ទោសនៅសល់ត្រូវព្យួរធម្មតា ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន 0២(ពីរ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ។

ច.ឈ្មោះ [redacted] វ៉ាននិត ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន 0២(ពីរ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២. បង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ហ៊ីម (ដូចមានក្នុងអត្តសញ្ញាណខាងលើ) យកទៅអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តសៀមរាប តាមអំណាចសាលក្រមនេះ។

៣. បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] វ៉ាន់និត តាមអំណាចសាលក្រមនេះ។

៤. បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៣៦៥/១៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ.២០១៦ តាមអំណាចសាលក្រមនេះ។

៥. វត្ថុចាប់យក ស្រោមសំបុត្រពណ៌ខ្លឹមខ្នុរ បិទជិតមានស្នាមមេដៃជនត្រូវចោទឈ្មោះ [redacted] វង្ហា ចំនួន ០១ (ឧបករណ៍ប្រើប្រាស់គ្រឿងញៀន) ដូចក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ ៨៤២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ សម្រេចរឹបអូស។

៦. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted]



Scanned by CamScanner

គឹមឡុក[redacted]ផ្កា [redacted] ចំរោះ [redacted]និកា និង [redacted] ភ័ន្តនិត និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នីណា និង[redacted] គឹមឡុង និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted] ហ៊ឹម ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា[redacted] | [redacted] | [redacted] | ហត្ថលេខា និងត្រា[redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

សៀមរាប,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចតចម្លងត្រឹមត្រូវចេញពី

ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប ថ្ងៃទី 19 ខែ[illegible]ឆ្នាំ២០១7

ក្រឡាបញ្ជី

**ហ៊ុន ឫទ្ធី**